# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤ សសរ

# សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតក្រុមការងារសម្របសម្រួលជាមួយសហគមន៍អ្នកផ្ដល់ជំនួយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

<u>ប្រការ ១</u> : ត្រូវបានបង្កើតក្រុមការងារមួយរបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលជាមួយសហគមន៍អ្នកផ្ដល់ជំនួយ និងគៀងគរជំនួយ ដើម្បីបំរើអោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្ដម ស ខេង | ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្ដម គាត ឈន់ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣-ឯកឧត្ដម សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤-ឯកឧត្ដម យូ ហុកគ្រី | ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្ដម ព្រុំ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |

៦-លោកជំទាវ ស៊ុន សារឿន អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ **សមាជិកា**

៧-ឯកឧត្តម នុត សារាន អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ **សមាជិក**

៨-ឯកឧត្តម សក់ សេដ្ឋា អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **សមាជិក**

៩-ឯកឧត្តម ចៅ វណ្ណលី អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **សមាជិកអចិន្ត្រៃយ៍**

**<u>ប្រការ ២</u>** : ក្រុមការងារនេះមានភារកិច្ច :

- សិក្សាប៉ាន់ប្រមាណអំពីតម្រូវការនានា សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងសហគមន៍អ្នកផ្តល់ជំនួយនានា ដើម្បីពិភាក្សាសម្រប សម្រួលស្វះស្វែងរកជំនួយបំរើអោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ពិភាក្សាស្វះស្វែងរកការគាំទ្រពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។
- រៀបចំអោយមានកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ឬជាមួយសហគមន៍អ្នកផ្តល់ជំនួយ ឬជាមួយសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិតាមការចាំបាច់ ។

**<u>ប្រការ ៣</u>** : ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងចំណាយថវិការបស់គណៈរដ្ឋមន្ត្រី ។

**<u>ប្រការ ៤</u>** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល :</u>**

*-ទីស្តីការក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
*-តំណាងអង្គការ UNDP ប្រចាំកម្ពុជា*
*- ដូចប្រការ៤*
*- ឯកសារ-កាលប្បវត្តិ*